## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការគ្រប់គ្រងសាលារៀនផ្ដោតលើលទ្ធផល

ឯកសារប្រតិបត្តិ

# លំនាំបង្រៀនមេរៀនភាសាខ្មែរ

ថ្នាក់ទី១-៣

សម្រាប់បឋមសិក្សា

ឆ្នាំ ២០១៧

# មាតិកា

## អារម្ភកថា

១- លំដាប់លំដោយដំណើរការរៀបចំសកម្មភាពរៀននិងបង្រៀន

ដ្យាក្រាមនៃការរៀបចំសកម្មភាពរៀននិងបង្រៀន

២- របៀបសរសេរលំនាំបង្រៀនមេរៀន

២.១ - ការកំណត់ខ្លឹមសារមេរៀនសម្រាប់សិស្សរៀននិងសម្រាប់បង្រៀនសិស្ស

២.២- ការកំណត់កិរិយាសព្ទសម្រាប់ឱ្យសិស្សធ្វើសកម្មភាពពេលសិក្សាខ្លឹមសារមេរៀន

២.៣- ការសរសេរលំដាប់លំដោយសកម្មភាពរៀននិងបង្រៀន

៣- ឯកសារឧបសម្ព័ន្ធ

ក-គោលការណ៍គរុកោសល្យ ក្នុងការការរៀបចំលំនាំគម្រោងបង្រៀនមេរៀនមួយ និងកិច្ចតែងការបង្រៀនខ-ការស្វែងយល់ពីគោលវិធីសិស្សមជ្ឈមណ្ឌល និងគ្រូមជ្ឈមណ្ឌលសម្រាប់អនុវត្តក្នុងពេលបង្រៀន

គ-ឯកសារជំនួយសម្រាប់គ្រូបង្រៀនក្នុងការសរសេរសកម្មភាពលម្អិតទៅតាមបំណិនអំណានពាក់ព័ន្ធជាមូលដ្ឋានក្នុងការសរសេរគម្រោងលំនាំបង្រៀនមេរៀនមួយ និងកិច្ចតែងការបង្រៀនថ្នាក់ទី១

ឃ-ឯកសារជំនួយសម្រាប់គ្រូបង្រៀនក្នុងការសរសេរគម្រោងលំនាំបង្រៀនមួយមេរៀនមានច្រើនម៉ោងសិក្សាដោយមានបង្ហាញតាមដំណាក់កាលមួយៗ ដោយមានគម្រោងលំនាំបង្រៀនមេរៀនមួយជាឧទាហរណ៍សម្រាប់ថ្នាក់ទី១។

ង-ឯកសារជំនួយសម្រាប់គ្រូបង្រៀនក្នុងការសរសេរកិច្ចតែងការបង្រៀនទៅតាមគម្រោងលំនាំបង្រៀនមេរៀនមួយដោយមានបង្ហាញឧទាហរណ៍កិច្ចតែងការបង្រៀនសរុបចំនួន ៤៧ ស្របទៅតាមកម្រិត ឬដំណាក់កាលទាំង៩ នៃសៀវភៅស្តង់ដាអំណានថ្នាក់ទី១

# អារម្ភកថា

ឯកសារណែនាំស្តីពី លំនាំការសរសេរគម្រោងលំនាំបង្រៀន មេរៀនភាសាខ្មែរ (អាន និងសរសេរ) ចងក្រងឡើងសម្រាប់ជួយ គ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ ក្នុងការសរសេរគម្រោងលំនាំបង្រៀនមេរៀននីមួយៗ តាមចំនួនម៉ោងមេរៀនខុសៗគ្នាក្នុង សៀវភៅសិក្សាគោល។ ពិសេសផ្តោតលើការសរសេរកិច្ចតែងការបង្រៀន សម្រាប់មួយម៉ោងសិក្សា លើមុខវិជ្ជាភាសាខ្មែរដោយផ្អែកលើការប្រើប្រាស់៖ សៀវភៅសិក្សាគោល សៀវភៅស្តង់ដាអំណាន និង កម្មវិធីសិក្សាលម្អិតភាសាខ្មែរសម្រាប់អប់រំមូលដ្ឋាន ចំណេះទូទៅ។ ការប្រើប្រាស់សៀវភៅស្តង់ដាអំណាន និង កម្មវិធី សិក្សាលម្អិត ផ្សារភ្ជាប់សៀវភៅសិក្សាគោលជាមូលដ្ឋាន ក្នុង ការសរសេរគម្រោងលំនាំបង្រៀន និងកិច្ចតែងការបង្រៀន មានន័យថាគ្រូបានបញ្ចូលវិធីឬល្បិចបង្រៀនព្រមទាំងការវាយតម្លៃ ដែលមានភាពទាក់ទាញ និងធ្វើឱ្យសិស្សមានការចាប់អារម្មណ៍ក្នុងការធ្វើសកម្មភាពសិក្សាឆ្លើយតបទៅនឹងលទ្ធផលសិក្សា ស្តង់ដាកម្មវិធីសិក្សាដែលក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ដើម្បីលើកកម្ពស់គុណភាពអប់រំស្របតាមកំណែទម្រង់ គុណភាពសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។

ដូច្នេះ ដើម្បីសរសេរគម្រោងលំនាំបង្រៀនមេរៀនគ្រូគប្បីរៀបចំការបង្រៀនទៅតាមដំណាក់កាលនីមួយៗ ដូចជា ការរៀបចំគម្រោងលំនាំបង្រៀនមេរៀនមួយដែលមានច្រើនម៉ោងសិក្សា ការសរសេរកិច្ចតែងការបង្រៀនមួយឬពីរម៉ោងសិក្សា ការដឹកនាំសកម្មភាពបង្រៀនតាមម៉ោងសិក្សា និងការវាយតម្លៃលទ្ធផលសិក្សាទៅតាម ដំណាក់កាល និងពេលបញ្ចប់មេរៀន ដើម្បីជួយគ្រូបង្រៀនឱ្យមើលឃើញពីទំនាក់ទំនងរវាងលទ្ធផលសិក្សា និងសកម្មភាពរៀនរបស់សិស្សនៅក្នុងមេរៀន។

គណៈកម្មការរៀបចំឯកសារសង្ឃឹមថា ឯកសារនេះនឹងបានជាមធ្យោបាយជំនួយស្មារតីដ៏ល្អក្នុងការពង្រឹងនូវវិធីឬ ល្បិចបង្រៀនរបស់គ្រូឱ្យកាន់តែសម្បូរបែបប្រកប ដោយគំនិតច្នៃប្រឌិតជាមួយនឹង ការប្រើប្រាស់សម្ភារឧបទេសស្របតាមលក្ខណៈវិទ្យាសាស្ត្រ និងបច្ចេកទេសនៃការអាន ដោយប្រើប្រាស់ធនធានដែលមានស្រាប់ក្នុងមូលដ្ឋាន ដើម្បីរួមចំណែកពង្រឹងសមត្ថភាពអាន និងសរសេររបស់សិស្សកាន់តែប្រសើរឡើង ឆ្លើយតបទៅនឹងគោលដៅនៃការអប់រំជាតិ។

# ១ លំដាប់លំដោយដំណើរការរៀបចំការរៀន និងបង្រៀន

ផ្នែកនេះនឹងបង្ហាញពីដ្យាក្រាមស្តីពីលំដាប់លំដោយ ដំណើរការរៀបចំការងាររៀន និងបង្រៀន ដែលក្នុងនោះមានៈ (១)ការរៀបចំគម្រោងលំនាំបង្រៀនមេរៀននីមួយៗ (២)ការសរសេរកិច្ចតែងការបង្រៀនមួយឬពីរម៉ោងសិក្សា (៣)ការដឹកនាំសកម្មភាពរៀននិងបង្រៀន និង(៤)ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ក្រោយពេលរៀនចប់មេរៀនមួយ។

ដើម្បីរៀបចំគម្រោងលំនាំបង្រៀន មេរៀនមួយបានប្រកបដោយគុណភាព លុះត្រាតែគ្រូបង្រៀនបានស្វែងយល់ពីមុខងារនិងសារៈសំខាន់របស់ៈ (១)សៀវភៅសិក្សាគោល (២)សៀវភៅស្តង់ដាអំណាន និង(៣)ឯកសារកម្មវិធីសិក្សាលម្អិតភាសាខ្មែរសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ ដើម្បីប្រើប្រាស់ក្នុងការកំណត់ខ្លឹមសារមេរៀន សម្រាប់សិស្សដែលត្រូវរៀន ដោយកំណត់កិរិយាសព្ទដែលមាននៅក្នុង លទ្ធផលសិក្សានិងក្នុងមេរៀននីមួយៗ ហើយឱ្យសិស្សធ្វើសកម្មភាពសិក្សាតាមលំដាប់លំដោយសកម្មភាពរៀននិងបង្រៀនរបស់គ្រូ។

លើសពីនេះ ដើម្បីរៀបចំគម្រោងលំនាំបង្រៀន មេរៀនមួយគ្រូបង្រៀនចាំបាច់ស្វែងយល់ ពីស្ថានភាពនិងបរិបទរស់នៅរបស់កុមារ ព្រមទាំងត្រូវដឹងពីសមត្ថភាពមានស្រាប់ និងសមត្ថភាពចាំបាច់ ដើម្បីសម្របសម្រួលការរៀបចំសកម្មភាព និងខ្លឹមសារបង្រៀនឱ្យបានសមស្រប នឹងឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស។

**ដ្យាក្រាមនៃការរៀបចំការងាររៀននិងបង្រៀន**



# ២ របៀបសរសេរគម្រោងលំនាំបង្រៀនមេរៀននីមួយៗ

## ២.១ ការកំណត់ខ្លឹមសារមេរៀនសម្រាប់សិស្សរៀន និងសម្រាប់បង្រៀនសិស្ស

ទី១ គ្រូបង្រៀនត្រូវកំណត់ ឬជ្រើសរើសមេរៀនណាមួយ ពីក្នុងសៀវភៅសិក្សាគោលទៅតាមតម្រូវការជាក់ស្តែង សម្រាប់សរសេរគម្រោងលំនាំបង្រៀន ដោយការកំណត់ចំណងជើងមេរៀន និងចំនួនម៉ោងបង្រៀន។ ជាទូទៅចំណងជើងមេរៀន និងចំនួនម៉ោងដែលគ្រូត្រូវបង្រៀននិងសិស្សត្រូវរៀន មានសរសេរនៅផ្នែកខាងលើនៃទំព័រដំបូងរបស់មេរៀននីមួយៗ។

ទី២ គ្រូបង្រៀនផ្ទៀងផ្ទាត់ចំណងជើងមេរៀន ទៅនឹងសៀវភៅស្តង់ដាអំណាន ដើម្បីស្រង់ខ្លឹមសារទៅតាមដំណាក់កាលនិងកម្រិតស្តង់ដានីមួយៗ។ សៀវភៅស្តង់ដាអំណានផ្តល់កម្រិតស្តង់ដាជាក់លាក់តិចឬច្រើន អាស្រ័យតាមដំណាក់កាលនីមួយៗ(ឧទាហរណ៍ ថ្នាក់ទី១ ដំណាក់កាលទី១ មានកម្រិតស្តង់ដាចំនួន៤ ពី១ក ដល់១ឃ ដំណាក់កាលទី២ មានកម្រិតស្តង់ដាចំនួន៥ ពី២ក ដល់២ង...។)។ នៅក្នុងកម្រិតស្តង់ដានីមួយៗ មានប្រាំមួយសមាសភាគ (១)សមត្ថភាពសិស្ស (២)បំណិនអំណានពាក់ព័ន្ធ (៣)ខ្លឹមសារ (មេរៀនក្នុងសៀវភៅសិក្សាគោល) (៤)សកម្មភាពគំរូ (សកម្មភាពបង្រៀនជាឧទាហរណ៍មួយចំនួន) (៥)ការវាយតម្លៃ(ការប្រើប្រាស់ឧបករណ៍តេស្តដំណាក់កាល) (៦)ល្បែងសិក្សា (សម្រាប់ការឆ្លើយតបនិងអន្តរាគមន៍ ជួយសិស្សដែលមានតម្រូវការរៀនបន្ថែម) ដែលសិស្សត្រូវសម្រេចបានពីការសិក្សា។

បន្ទាប់ពីបានជ្រើសរើសខ្លឹមសារ ក្នុងសៀវភៅស្តង់ដាអំណានទាំង៦សមាសភាគ ខាងលើមកបង្រៀនរួច គ្រូបង្រៀនអាចពិនិត្យមើលឡើងវិញ ដោយធ្វើការបំពេញបន្ថែមខ្លឹមសារមួយចំនួនទៀត ពីសៀវភៅសិក្សាគោល ព្រោះខ្លឹមសារដែលបានស្រង់ពីសៀវភៅស្តង់ដាអំណាន បានរៀបចំសម្រាប់ជួយគ្រូ ប្រើប្រាស់បំណិនអំណានទាំង៥ និងផ្តល់ កម្រិតស្តង់ដាជាក់លាក់ ក្នុងដំណើរការបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សតាមដំណាក់កាលឬពេលបញ្ចប់មេរៀននីមួយៗ។

ឧទាហរណ៍ គម្រោងសរសេរលំនាំបង្រៀនមេរៀនទី១៦ គ (ព្យញ្ជនៈពួកអ៊ )

ក ការស្គាល់សូរ ការស្គាល់តួអក្សរ និងសូរ

- ស្រៈនិស្ស័យទាំងអស់

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ

ុំ ំ ាំ ះ ុះ េះ ោះ

- ព្យញ្ជនៈពួក អ៊ ទាំង ១៨ តួ

គ ឃ ង ជ ឈ ញ ឌ ឍ ទឍ ន ព ភ ម យ រ ល វ

- ព្យាង្គទាំងអស់ដែលកើតឡើងដោយការប្រកបផ្សំសូរព្យញ្ជនៈនិងស្រៈនិស្ស័យ

គ គា គិ គី គឹ គឺ គុ គូ គួ គឿ គៀ គេ គែ គៃ គោ គៅ គុំ គំ គាំ គះ គុះ គេះ គោះ

- ព្យាង្គ និងពាក្យទាំងអស់ដែលកើតឡើងដោយការប្រកប និងផ្សំសូរព្យញ្ជនៈពួក(អ៊ ) និងស្រៈនិស្ស័យក្នុងមេរៀនទី១៦

គ គា គិ គី គឹ គឺ គុ គូ គួ គឿ គៀ គេ គែ គៃ គោ គៅ គុំ គំ គាំ គះ គុះ គេះ គោះ

គេ គែ គោ គុំ គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ)សាគូ អគា(រ) គគី(រ)

ខ ការចេះវាក្យសព្ទ ការចេះអានស្ទាត់

- ពាក្យទាំងអស់ដែលមានក្នុងមេរៀនទី១៦

គេ គែ គោ គុំ គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ)សាគូ អគា(រ) គគី(រ)

គ ការចេះអានស្ទាត់

- ពាក្យទាំងអស់ដែលកើតឡើងដោយការប្រកបនិងផ្សំសូរព្យញ្ជនៈនិងស្រៈនិស្ស័យ

គេ គែ គោ គុំ គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ)សាគូ អគា(រ) គគី(រ)

ឃ ការអានដើម្បីយល់ន័យ

- ឃ្លានិងល្បះខ្លីៗទាំងអស់ដែលបង្កើតឡើងដោយវាក្យសព្ទក្នុងមេរៀនទី ១៦

ថៅគាគូរគោ ។ តាគីបេះគ ។

## ២.២ ការកំណត់កិរិយាសព្ទសម្រាប់ឱ្យសិស្សធ្វើសកម្មភាពពេលសិក្សាខ្លឹមសារមេរៀន

**ទី១** គ្រូបង្រៀនត្រូវសិក្សា ឯកសារកម្មវិធីសិក្សាលម្អិតភាសាខ្មែរ សម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ ថ្នាក់ទី១ ដល់ទី៩ ដែលបោះពុម្ពឱ្យប្រើប្រាស់ ដោយក្រសួងអប់រំនៅឆ្នាំ២០០៦។ បន្ទាប់មកបើកទៅទំព័រដែលសរសេរថា "លទ្ធផលសិក្សា ភាសាខ្មែរ" ថ្នាក់ទី១ទំព័រទី១ ថ្នាក់ទី២ទំព័រទី៨ ថ្នាក់ទី៣ទំព័រ១៤។

**ទី២** គ្រូបង្រៀនស្រង់កិរិយាសព្ទ ដែលបានសរសេរនៅក្នុងឈ្មោះនីមួយៗ ក្នុងតារាងលទ្ធផលសិក្សារួមទៅតាមសមត្ថភាពទាំង៤ (ការស្តាប់ ការនិយាយ ការអាន ការសរសេរ)។ បន្ទាប់មក គ្រូបន្តទៅស្រង់កិរិយាសព្ទមួយចំនួនទៀត នៅក្នុងលទ្ធផលសិក្សាតាមមេរៀននីមួយៗ ដើម្បីរៀបចំខ្លឹមសារមេរៀន តាមលំដាប់លំដោយសកម្មភាព រៀននិងបង្រៀនក្នុងគម្រោងលំនាំមេរៀននីមួយៗ។

ឧទាហរណ៍ តារាងសម្រង់កិរិយាសព្ទពីលទ្ធផលសិក្សាភាសាខ្មែរថ្នាក់ទី១

<u>សម្គាល់</u>៖ ចំពោះពាក្យដែលមានអក្សរដិត ជាកិរិយាសព្ទបន្ថែម

| | | | | |
|---|---|---|---|---|
| ស្តាប់ | បង្ហាញ | អាន | សរសេរ | ញែក |
| ប្រកបនិងផ្សំ | ចម្លង | ភ្ជាប់ | រៀប | ប្រើ |
| **រក** | **ជ្រើសរើស** | **ផ្ទៀងផ្ទាត់** | **ប្រាប់** | |

## ២.៣ ការសរសេរលំដាប់លំដោយសកម្មភាពរៀន និងបង្រៀន

ទី១ គ្រូបង្រៀនត្រូវយកខ្លឹមសារ សម្រាប់សិស្សរៀនដែលបានរៀបចំរួច រៀបតាមលំដាប់លំដោយសកម្មភាព រៀន និងបង្រៀនដូចខាងក្រោម។

ឧទាហរណ៍៖ ភាសាខ្មែរថ្នាក់ទី១ ខ្លឹមសារដែលបានរៀបចំ តាមលំដាប់លំដោយរបស់មេរៀនទី១៦ មានរយៈពេលបង្រៀន៦ម៉ោង។ ខ្លឹមសារដែលសិស្សត្រូវរៀន ដើម្បីទទួលបានបំណិន៖

## ក ការស្គាល់សូរ ការស្គាល់តួអក្សរ និងសូរ

១ ស្រៈនិស្ស័យទាំងអស់

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ

ុំ ំ ាំ ះ ុះ េះ ោះ

២ ព្យញ្ជនៈពួក អ៊ ទាំង ១៨ តួ

គ ឃ ង ជ ឈ ញ ឌ ឍ ទឍ ន ព ភ ម យ រ ល វ

៣ ព្យាង្គទាំងអស់ដែលកើតឡើងដោយការប្រកបផ្សំសូរព្យញ្ជនៈនិងស្រៈនិស្ស័យ

គ គា គិ គី គឹ គឺ គុ គូ គួ គឿ គៀ  គេ  គែ គៃ គោ គៅ គុំ គំ គាំ គះ គុះ គេះ គោះ

៤ ព្យាង្គ និងពាក្យទាំងអស់ដែលកើតឡើងដោយការប្រកប និងផ្សំសូរព្យញ្ជនៈពួក(អ៊ី) និងស្រៈនិស្ស័យក្នុងមេរៀនទី១៦

គ គា គិ គី គឹ គឺ គុ គូ គួ គឿ គៀ គេ គែ គៃ គោ គៅ គុំ គំ គាំ គះ គុះ គេះ គោះ

គេ គែ គោ គុំ  គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ)សាគូ អគា(រ) គគី(រ)

## ខ ការចេះវាក្យសព្ទ ការចេះអានស្ទាត់

១ ពាក្យទាំងអស់ដែលមានក្នុងមេរៀនទី១៦

គេ គែ គោ គុំ  គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ)សាគូ អគា(រ) គគី(រ)

## គ ការចេះអានស្ទាត់

២ ពាក្យទាំងអស់ដែលកើតឡើងដោយការប្រកបនិងផ្សំសូរព្យញ្ជនៈនិងស្រៈនិស្ស័យ

គេ គែ គោ គុំ  គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ)សាគូ អគា(រ) គគី(រ)

## ឃ ការអានដើម្បីយល់ន័យ

១ ឃ្លានិងល្បះខ្លីៗទាំងអស់ដែលបង្កើតឡើងដោយវាក្យសព្ទក្នុងមេរៀនទី ១៦

ចៅគាគូរគោ ។  តាគីបេះគ ។

ឧទាហរណ៍ ការបង្ហាញពីរបៀបសរសេរ លំដាប់លំដោយសកម្មភាពរៀននិងបង្រៀន ទៅតាមបំណិននីមួយៗទាំង៤ខាងលើ (ក) (ខ) (គ) និង(ឃ)។

### ក ការស្គាល់សូរ ការស្គាល់តួអក្សរ និងសូរ

- ស្រៈនិស្ស័យទាំងអស់ ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ុះ េះ ោះ
- ព្យញ្ជនៈពួក អ៊ី ទាំង ១៨ តួ គ ឃ ង ជ ឈ ញ ឌ ឍ ទ ធ ន ព ភ ម យ រ ល វ
- ព្យាង្គទាំងអស់ដែលកើតឡើងដោយការប្រកបផ្សំសូរព្យញ្ជនៈនិងស្រៈនិស្ស័យ គ គា គិ គី គឹ គឺ គុ គូ គួ គឿ គៀ  គេ គែ គៃ គោ គៅ គុំ គំ គាំ គះ គុះ គេះ គោះ
- ព្យាង្គ និងពាក្យទាំងអស់ដែលកើតឡើងដោយការប្រកប និងផ្សំសូរព្យញ្ជនៈពួក(អ៊ី) និងស្រៈនិស្ស័យក្នុងមេរៀនទី១៦ គេ គែ គោ គុំ  គោះ គ(រ) គូ(រ)គួ(រ) គោបា  សាគ(រ)សាគូ អគា(រ) គគី(រ)

| សកម្មភាពសិស្ស | ខ្លឹមសារសកម្មភាព |
|---|---|
| សិស្សផ្សំសូរព្យញ្ជនៈពួកអ៊ី ដើម្បីអានព្យាង្គនិងពាក្យ | |

| បានត្រឹមត្រូវ | |
|---|---|
| | |

១ អានស្រៈនិស្ស័យទាំងអស់ ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌េ ◌ែ◌ៃ ◌ោ◌ៅ ◌ុំ ◌ំ ◌ាំ ◌ះ◌ុះ ◌េះ ◌ោះ ដោយ៖ប្រាប់ឈ្មោះ សត្វ ទីកន្លែង តាមលំដាប់ មិនតាមលំដាប់ បញ្ច្រាស

| ស្រៈនិស្ស័យទាំអអស់ | | | | | |
|---|---|---|---|---|---|
| ◌ា | ◌ិ | ◌ី | ◌ឹ | ◌ឺ | ◌ុ |
| ◌ូ | ◌ួ | ◌ឿ | ◌ៀ | ◌េ | ◌ែ |
| ◌ៃ | ◌ោ | ◌ៅ | ◌ុ | ◌ំ | ◌ាំ |
| ◌ះ | ◌េះ | ◌ុះ | ◌ោះ | | |

២ អានព្យញ្ជនៈពួកអឺទាំង១៨តួ គ ឃ ង ជ ឈ ញ ឌ ឍ ទ ធ ន ព ភ ម យ រ ល វ ដោយ៖រកឈ្មោះ សត្វ រុក្ខជាតិ ទីកន្លែង តាមលំដាប់ មិនតាមលំដាប់ បញ្ច្រាស

| ព្យញ្ជនៈពួក អឺ ទាំង១៨តួ | | | | | |
|---|---|---|---|---|---|
| គ | ឃ | ង | ជ | ឈ | ញ |
| ឌ | ឍ | ទ | ធ | ន | ព |
| ភ | ម | យ | រ | ល | វ |

៣ ប្រកបនិងផ្សំស្សរ ព្យញ្ជនៈ គ ជាមួយ ស្រៈនិស្ស័យទាំងអស់ ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌េ ◌ែ◌ៃ ◌ោ◌ៅ ◌ុំ ◌ំ . .◌ាំ ◌ះ ◌េះ ◌ោះ ដោយ៖បង្ហាញ ឈ្មោះ សត្វ ទីកន្លែង រុក្ខជាតិ និង សកម្មភាព

| ព្យញ្ជនៈ | សូរស្រៈ | ព្យាង្គ |
|---|---|---|
| គ | អ៊ា«◌ា» | គា |
| ……… | ……… | ……… |
| គ | អ៊េះ«◌េះ» | គេះ |
| គ | អ៊ោះ«◌ោះ» | គោះ |

៤ អានព្យាង្គទាំងអស់ដែលកើតឡើងដោយការប្រកបនិងផ្សំស្សរ ព្យញ្ជនៈ និងស្រៈនិស្ស័យ គ គា គិ គី គឹ គឺ គុ គូ គួ គឿ គៀ គេ គែ គៃ គោ គៅ គុំ គំ គាំ គះ គុះ គេះ គោះ ដោយ៖តាមលំដាប់ មិនតាមលំដាប់ បញ្ច្រាស

| ព្យាង្គ | អានថា |
|---|---|
| គេ | គេ |
| គែ | គែ |
| គោះ | គោះ |
| …… | …………… |

៥ អានពាក្យទាំងអស់ដែលកើតឡើងដោយការផ្សំព្យាង្គ គ គា គិ គី គឹ គឺ គុ គូ គួ គឿ គៀ គេ គែ គៃ គោ គៅ គុំ គំ គាំ គះ គុះ គេះ គោះ ដោយ៖ តាមលំដាប់ មិនតាមលំដាប់ បញ្ច្រាស

| ពាក្យផ្សំព្យាង្គ | អានថា |
|---|---|
| អគារ | អាក់ គា |
| សគ្គ | សាគ |
| គគីរ | គ- គី |
| ……… | ………… |

## ខ ការចេះវាក្យសព្ទ និងការចេះអានស្ទាត់

- ពាក្យទាំងអស់ដែលមានក្នុងមេរៀនទី ១៦៖ គោ គូរ អគារ

| សកម្មភាពសិស្ស | ភស្តុតាងនៃលទ្ធផលការសិក្សារបស់សិស្ស |
|---|---|

**១ សិស្សប្រាប់ពាក្យទាំងអស់ដែលមានក្នុងមេរៀនទី១៦**

- ប្រាប់ស្រៈ និងព្យញ្ជនៈ ពាក្យ គោ គូរ អគារ

| ពាក្យ | ស្រៈ និងព្យញ្ជនៈ | | | | | | |
|---|---|---|---|---|---|---|---|
| គោ | ោ | គ | | | | | |
| គូរ | ូ | គ | រ | | | | |
| អគារ | ា | អ | គ | រ | | | |

- ប្រកបពាក្យ ពាក្យ "គោ គូរ អគារ"

| ពាក្យ | ប្រកប | | | |
|---|---|---|---|---|
| គោ | គ | អោ | | គោ |
| គូរ | គ | អូ(រ) | | គូ(រ) |
| អគារ | អ | គ | អា(រ) | អគា(រ) |

- អានពាក្យ "គោ គូរ អគារ"

| ពាក្យ | សូរពាក្យ | អានថា |
|---|---|---|
| គោ | គ អោ | គោ |
| គូរ | គ អូ(រ) | គូ (រ) |
| អគារ | អៈ គ អា(រ) | អៈ គា (រ) |

- គូសរង្វង់ជុំវិញពាក្យ "គោ គូរ អគារ" ឱ្យត្រូវនឹងរូបភាព

គូសរង្វង់ជុំវិញពាក្យខាងក្រោមឱ្យត្រូវ នឹងរូបភាព

| រូបភាព និងពាក្យ | | | |
|---|---|---|---|
| រូបមនុស្សរាំ | រៃ | រាំ | រៈ |
| រូបគោ | គូ | គុំ | គោ |
| រូបអគារ | គោះ | អគារ | គគីរ |
| រូបរទេះ | រទេះ | ទុំ | ទា |

- ផ្គូផ្គងពាក្យ "គោ គូរ អគារ" ឱ្យត្រូវនឹងរូបភាព

ផ្គូផ្គងពាក្យខាងក្រោមឱ្យត្រូវ នឹងរូបភាព

| ពាក្យ | រូបភាព |
|---|---|
| គោ | រូបអគារ |
| គូ (រ) | រូបគោ |
| អគារ | រូបគូរ |

## ខ ការបេះវាក្យសព្ទ ការបេះអានស្ទាត់

- ពាក្យទាំងអស់ដែលមានក្នុងមេរៀនទី១៦ គេ គែ គោ គុំ គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ) សាគូ អគា(រ) គគី(រ)

| សកម្មភាពសិស្ស | ខ្លឹមសារសកម្មភាព |
|---|---|
| សិស្សអាន និងប្រើការចំណាំពាក្យមួយព្យាង្គ ពីរព្យាង្គដែលប្រើញឹកញាប់ | |

១ ប្រាប់ឈ្មោះព្យញ្ជនៈ និងស្រៈនិស្ស័យ របស់ពាក្យ គេ គែ គោ គុំ គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ)សាគូ អគា(រ) គគី(រ) ដោយៈ ជ្រើសរើសចំនួន ស្រៈ ព្យញ្ជនៈនៅក្នុងតារាងបញ្ជីពាក្យ

| ពាក្យ | ស្រៈ និងព្យញ្ជនៈ | | | | | | |
|---|---|---|---|---|---|---|---|
| គេ | ◌េ | គ | | | | | |
| គែ | ◌ែ | គ | | | | | |
| គោ | ◌ោ | គ | | | | | |
| គូរ | ◌ូ | គ | រ | | | | |
| អគារ | ◌ា | អ | គ | រ | | | |
| …… | …… | …… | …… | …… | …… | …… | …. |

២ ប្រកបពាក្យ គេ គែ គោ គុំ គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ)សាគូ អគា(រ) គគី(រ) ប្រាប់ពាក្យដោយផ្សំ ព្យញ្ជនៈ ស្រៈ រួចបបន្លឺសូរសំលេងពួកអ៊ែនៅក្នុងតារាងបញ្ជីពាក្យ

| ពាក្យ | ប្រកប | | | | |
|---|---|---|---|---|---|
| គោ | គ | អ៊ោ | | | |
| គូរ | គ | អ៊ូ(រ) | | | |
| អគារ | អ | គ | អ៊ា(រ) | | |
| …….. | ……. | ………. | ………. | ………. | ………. |

៣ អានពាក្យ គេ គែ គោ គុំ គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ)សាគូ អគា(រ) គគី(រ) ដោយៈ មិនប្រកប មិនរំលង មិនស្ទួន មិនលើស

| ពាក្យ | អានថា |
|---|---|
| គោ | គោ |
| គូរ | គូ (រ) |
| អគារ | អាក់-គា (រ) |
| ….. | ………………… |

## គ ការបេះអានស្ទាត់

- ពាក្យទាំងអស់ដែលកើតឡើងដោយការប្រកបនិងផ្សំសូរព្យញ្ជនៈនិងស្រៈនិស្ស័យក្នុងមេរៀនទី១៦ គេ គែ គោ គុំ គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ)សាគូ អគា(រ) គគី(រ)

| សកម្មភាពសិស្ស | ខ្លឹមសារសកម្មភាព |
|---|---|
| សិស្សអានពាក្យដែលផ្សំពីព្យញ្ជនៈពួក (អ៊ិ) បានស្ទាត់ | |

១ រាប់ចំនួនស្រៈនិស្ស័យ និង ព្យញ្ជនៈ របស់ពាក្យ គេ គែ គោ គុំ គោះ គ(រ) គូ(រ)គួ(រ) គោបា

| ពាក្យ | ស្រៈ និងព្យញ្ជនៈ |
|---|---|

សាគ(រ)សាគូ អគា(រ) គគី(រ) ដោយះ រាប់ស្រៈ និង ព្យញ្ជនៈ ទៅតាមពាក្យនីមួយៗដែលបានកំណត់តាមរូបភាព

| | | | | | | | |
|---|---|---|---|---|---|---|---|
| គេ | េ◌ | គ | | | | | |
| គែ | ែ◌ | គ | | | | | |
| គោ | ោ◌ | គ | | | | | |
| គូរ | ◌ូ | គ | រ | | | | |
| អ◌ារ | ◌ា | អ | គ | រ | | | |
| ……... | …… | …… | …… | …… | …… | …… | |

២ ប្រកបពាក្យ គេ គែ គោ គុំ គោះ គ(រ) គូ(រ)គួ(រ) គោបា សាគ(រ)សាគូ អគា(រ) គគី(រ) ដោយះប្រាប់ពាក្យដោយ ផ្សំ ព្យញ្ជនៈ ស្រៈ រួចបបន្លឺសូរសំលេងពួកអ៊ែនៅក្នុងបញ្ជីពាក្យ

| ពាក្យ | ប្រកប | អានថា |
|---|---|---|
| គេ | គ េ◌ | គេ |
| គោះ | គ ោ◌ះ | គោះ |
| គោ | គ ោ◌ | គោ |
| គូ (រ) | គ ◌ូ | គូ (រ). |
| ………………. | …………………….. | ………………. |

## ឃ ការអានដើម្បីយល់ន័យ

- ឃ្លា និង ល្បះខ្លីៗទាំងអស់ដែលបង្កើតឡើងដោយវាក្យសព្ទក្នុងមេរៀនទី ១៦ គោបា សាគ(រ)សាគូ អគា(រ)គគី(រ) និង ចៅគាគូរគោ។ តាគីបេះគ ។

| សកម្មភាពសិស្ស | ខ្លឹមសារសកម្មភាព |
|---|---|
| | |

សិស្សអានឃ្លានិងល្បះខ្លីៗដោយយល់ន័យ

១ អានឃ្លា គោបា សាគ(រ)សាគូ អគា(រ)គគី(រ ) ដោយះដក ឬ លុបព្យញ្ជនៈ ស្រៈរបស់ពាក្យ នីមួយៗ ឱ្យបានត្រឹមត្រូវ

| ឧទាហរណ៍ | | | | | |
|---|---|---|---|---|---|
| គោបា | គ | េ◌ | | ◌ា | |
| សាគ(រ) | ស | | | រ | |
| សាគូ | | គូ | រ | | |
| ………….. | … | ……... | ……... | ……... | |

២ អានល្បះ ចៅគាគូរគោ។ តាគីបេះគ។ ដោយះ ដកឬលុប ពាក្យ របស់ល្បះ នៅក្នុងបញ្ជីពាក្យ ឱ្យបានត្រឹមត្រូវ

| ឧទាហរណ៍ | | | | | |
|---|---|---|---|---|---|
| ចៅគាគូគោ។ | ចៅ | គា | | គោ។ | |
| តាគីបេះគ។ | គា | | បេះ | | |
| …… | …. | … | … | … | … |

៣ រៀប គោបា សាគ(រ)សាគូ អគា(រ)គគី(រ ) និង ល្បះ ចៅគាគូគោ។ តាគីបេះគ។ ឡើងវិញឱ្យបានត្រឹមត្រូវ

| ឧទាហរណ៍ | | | | | |
|---|---|---|---|---|---|
| គោបា | គ | ◌ា | ប | េ◌ | |
| សាគរ | ស | គ | ◌ា | រ | |

| | | |
|---|---|---|
| ៤ | តែងល្បះទៅតាមរូបភាពឱ្យមានន័យគ្រប់គ្រាន់<br>គោស៊ីស្មៅ។ នេះជា អគារ ។.....<br>ដោយ៖ មើលរូបភាពហើយសំណួរ-ឆ្លើយ | (see tables below) |

| | | | | | |
|---|---|---|---|---|---|
| …. | ….. | …… | …… | ….. | …… |
| ចៅតា គូគោ។ | គោ។ | គា | ចៅ | គូរ | |
| តាគី បេះគ។ | តា | គ។ | បេះ | គី | |
| … | …… | …… | …… | …… | …… |

| ឧទាហរណ៍ | | | | | |
|---|---|---|---|---|---|
| រូបគោ | គោ | ស៊ី | ស្មៅ | | |
| រូប អគារ | នេះ | ជា | អគារ | | |
| …. | ….. | …… | …… | ….. | …… |

# ៣ ឯកសារឧបសម្ព័ន្ធ

## ក. គោលការណ៍គរុកោសល្យ ក្នុងការការរៀបចំលំនាំគម្រោងបង្រៀនមេរៀនមួយ និងកិច្ចតែងការបង្រៀន

ការជួយគ្រូបង្រៀន ក្នុងការសរសេរកិច្ចតែងការបង្រៀន និងការបង្ហាញសកម្មភាពបង្រៀនជាក់ស្តែង រវាងគ្រូបង្រៀនជាមួយសិស្ស ដែលប្រព្រឹត្តទៅជាប្រចាំនៅតាបថ្នាក់រៀន ជាកត្តាចំបងនិងមានសារៈសំខាន់បំផុត។ ប៉ុន្តែបញ្ហាប្រឈមនោះ គឺការជួយគ្រូបង្រៀនឱ្យអាចកំណត់បានពីស្រទាប់ ឬកម្រិតរបស់វិធីសាស្ត្របង្រៀន និងការរៀបចំកិច្ចតែងការបង្រៀន ដើម្បីអាចឱ្យគាត់មានទំនុកចិត្ត ដោយសារការយល់ដឹង ក្នុងការប្រើប្រាស់ប្រភេទ និងកម្រិតវិធីសាស្ត្របង្រៀន។

**គោលវិធី (Approach)** គឺជាកម្រិតទ្រឹស្តី និងកម្រិតគំរូលំនាំនៃការសិក្សា ដែលបានមកពីការសិក្សាស្រាវជ្រាវ និងជាគំនិតផ្តួចផ្តើមជាចម្បង ដែលមានលក្ខណៈសកល។ ឧទាហរណ៍៖ ការអាន ត្រូវបានចែកលម្អិតជា (១)អានដើម្បីស្គាល់សូរ (២)អានដើម្បីស្គាល់តួអក្សរនិងសូរ (៣)អានដើម្បីការអានស្ទាត់ (៤)អានដើម្បីការចេះវាក្យសព្ទ និង(៥)អានដើម្បីយល់ន័យ)។ ដូច្នេះគោលវិធី (Approach) គឺប្រើសម្រាប់ការសរសេរគម្រោងលំនាំបង្រៀនមេរៀនមួយ។

**វិធីសាស្ត្របង្រៀន (Method)** គឺជានីតិវិធី របៀប មធ្យោបាយ ដំណើរការ ឬលំដាប់លំដោយសកម្មភាពសិក្សា សំដៅសម្រេចគោលវិធី (Approach)។ ឧទាហរណ៍៖ ដើម្បីអាចឱ្យសិស្សមានសមត្ថភាពស្គាល់សូរ ឬស្គាល់តួអក្សរ តើសិស្សត្រូវធ្វើសកម្មភាពអ្វីខ្លះ។ សកម្មភាពទាំងនេះគឺស្ថិតក្នុងកម្រិត វិធីសាស្ត្របង្រៀន (Method) ជាកម្រិតបន្ទាប់ពីគោលវិធី (Approach)។ ដូច្នេះវិធីសាស្ត្របង្រៀន (Method) គឺប្រើសម្រាប់ការសរសេរគម្រោងលំនាំបង្រៀនមេរៀនមួយផង និងកិច្ចតែងការបង្រៀនមួយម៉ោងសិក្សាផង។

**វិធី ល្បិច របៀប ឬបច្ចេកទេសបង្រៀន (Technique)** គឺជាល្បិចបង្រៀនរបស់គ្រូម្នាក់ៗ ដែលជាទូទៅវាមិនអាចមានដូចគ្នាទេ គឺវាអាស្រ័យទៅតាមស្ថានភាព មធ្យោបាយ ធនធាន និងទេពកោសល្យរបស់លោកគ្រូអ្នកគ្រូម្នាក់ៗ។ វិធីបង្រៀនសំដៅលើការរៀបចំសកម្មភាពរៀន និងបង្រៀនតាមរយៈការដាក់កិច្ចការ ឬការងារឱ្យសិស្សធ្វើសកម្មភាព នៅក្នុងថ្នាក់រៀនដែលមានភាពជាក់លាក់ ផ្អែកលើកិច្ចតែងការបង្រៀនរបស់លោកគ្រូអ្នកគ្រូ។ ដូច្នេះគ្រូបង្រៀនគួរចងចាំថា វិធីបង្រៀនមិនដូចគ្នានឹងគោលវិធី ឬវិធីសាស្ត្របង្រៀនទាំងស្រុងនោះទេ វាគឺជាការអនុវត្តសកម្មភាពបង្រៀនជាក់ស្តែង នៅក្នុងថ្នាក់រៀន ដែលគេហៅថា វិធី ល្បិច របៀប ឬបច្ចេកទេសបង្រៀន (Technique)។

## ខ. ការស្វែងយល់ពីគោលវិធីសិស្សមជ្ឈមណ្ឌល និងគ្រូមជ្ឈមណ្ឌលសម្រាប់អនុវត្តក្នុងពេលបង្រៀន

ពាក្យថាវិធីសាស្ត្របង្រៀន មានទំនាក់ទំនងទៅនឹងគោលការណ៍ទូទៅ នៃយុទ្ធសាស្ត្រគ្រប់គ្រងគរុកោសល្យ ប្រើសម្រាប់ការបង្រៀនក្នុងថ្នាក់រៀន។ ការជ្រើសរើសវិធីសាស្ត្របង្រៀនរបស់អ្នក គឺផ្អែកលើភាពសមស្របទៅនឹង ទស្សនៈវិជ្ជាប្រជាសាស្ត្រក្នុងថ្នាក់រៀន មុខវិជ្ជា និងបេសកកម្មរបស់សាលារៀន។ ទ្រឹស្តីនៃការបង្រៀន មានការបែងចែកជាពីប្រភេទ (categories) ឬជាពីវិធីសាស្ត្រ(approaches) គឺគោលវិធីគ្រូមជ្ឈមណ្ឌល (teacher centered) និងសិស្សមជ្ឈមណ្ឌល (student centered)។

**គោលវិធីគ្រូមជ្ឈមណ្ឌលៈ** គោលវិធីគ្រូមជ្ឈមណ្ឌល មានន័យថាគ្រូបង្រៀនមានអំណាចចាត់ចែងឱ្យសិស្សរៀន ដោយមើលឃើញថាសិស្សជាធុងទទេរ (empty vessels) ដែលគ្រូបង្រៀនមានភារកិច្ចសំខាន់ ក្នុងការចាក់បំពេញ ដែលសិស្សត្រូវតែទទួលព័ត៌មានតាមរយៈការរ៉ាយរ៉ាប់ និងការនិយាយប្រាប់ (lectures and direct instruction) និងនៅទីបញ្ចប់នឹងមានការតេស្តនិងវាយតម្លៃ។ គោលវិធីនេះគឺគ្រូបង្រៀនមានតួនាទីចំបង ក្នុងការផ្ទេរចំណេះដឹង និងប្រាប់ព័ត៌មានទៅសិស្ស។ ក្នុងការអនុវត្តគោលវិធីនេះ ការបង្រៀន និងវាយតម្លៃការសិក្សា ត្រូវបានចែកដាច់ពីគ្នា។ ការវាយតម្លៃការសិក្សារបស់សិស្ស គឺតាមរយៈពិន្ទុតេស្ត និងប្រឡង។

**គោលវិធីសិស្សមជ្ឈមណ្ឌលៈ** គោលវិធីសិស្សមជ្ឈមណ្ឌល មានន័យថាគ្រូបង្រៀនមានសមត្ថកិច្ចចាត់ចែងឱ្យសិស្សរៀនដោយគ្រូបង្រៀន និងសិស្សមានតួនាទីសកម្មដូចគ្នា នៅក្នុងដំណើរការរៀននិងបង្រៀន។ តួនាទីចំបងរបស់គ្រូបង្រៀនគឺជាអ្នកបង្វឹក និងជាអ្នកសម្របសម្រួលដល់ការសិក្សារបស់សិស្សទូទៅ ដោយមានសំភារៈឧបទេស និងឯកសារប្រកបដោយការយល់ដឹង។ ចំពោះការវាយតម្លៃការសិក្សាសិស្ស គឺមានការវាយតម្លៃការសិក្សាបណ្តើៗ និងពេលចប់មេរៀន រួមនឹងការងារក្រុម និងការចូលរួមរបស់សិស្សក្នុងដំណើរការសិក្សា។ ការបង្រៀន និងការវាយតម្លៃមានទំនាក់ទំនងគ្នា ការវាយតម្លៃការសិក្សារបស់សិស្សប្រព្រឹត្តទៅ ជាមួយគ្នាក្នុងដំណើរការបង្រៀន។

ដើម្បីយល់ដឹងឱ្យកាន់តែប្រសើរថែមទៀត ចំពោះវិធីសាស្ត្រនេះ វាជាការចាំបាច់គួរមានការពិភាក្សា ឱ្យមានការយល់ដឹងទៅលើរបៀបបង្រៀនទាំងបីយ៉ាង(three main teaching styles) ក្នុងគរុកោសល្យអប់រំ ក្នុងនោះមាន (១) ការបង្រៀនដោយនិយាយប្រាប់/រ៉ាយរ៉ាប់ "direct instruction" (២) ការសិក្សាផ្អែកលើការស្រាវជ្រាវ "inquiry-based learning" និង (៣)ការរៀនតាមបែបសហការណ៍ "cooperative learning"។ តាមរយៈវិធីសាស្ត្របង្រៀនទាំងបីនេះ គ្រូបង្រៀនអាចទទួល

បានការយល់ដឹង ពីរបៀបគ្រប់គ្រងថ្នាក់ដែលគាត់បង្រៀន ការបង្រៀនរបស់គាត់ និងការផ្សារភ្ជាប់ជាមួយសិស្ស (Theorist A.F. Grasha 1996)។

(ក) វិធីសាស្ត្រវ៉ាយវ៉ាប់"direct instruction"៖ គឺជារបៀបបង្រៀនតាមរបៀបបូរាណ "Traditional teaching" ប្រើការវ៉ាយវ៉ាប់ ឬបឋកថា "lecture" និងការបង្រៀនដោយគ្រូជាអ្នកដឹកនាំ ក្នុងការបង្ហាញឱ្យមើល "demonstration"។ វិធីសាស្ត្របង្រៀនវ៉ាយវ៉ាប់ "direct instruction" ស្ថិតនៅក្រោមយុទ្ធសាស្ត្របង្រៀន **<u>គោលវិធីគ្រូមជ្ឈមណ្ឌល</u>** ដែលគ្រូបង្រៀន និងសាស្ត្រាចារ្យ គឺជាស្នូលក្នុងការផ្តល់ចំណេះដឹង និងព័ត៌មាន។ វិធីសាស្ត្របង្រៀនដោយវ៉ាយវ៉ាប់ "direct instruction" គឺមានប្រសិទ្ធភាព ប្រើជាមូលដ្ឋាននៃការបង្រៀន និងជាបំណិនគ្រឹះសម្រាប់ការបង្រៀន ទៅលើគ្រប់មុខវិជ្ជានិងមេរៀន។

| **សមត្ថកិច្ច**<br><br>Formal authority | **ឯកទេស**<br><br>Expert | **តាមគម្រូខ្លួនបុគ្គល/**<br><br>Personal model |
|---|---|---|
| គ្រូបង្រៀនសមត្ថកិច្ច គឺជាអ្នកមានជំហរក្នុងការប្រើប្រាស់អំណាច និងសមត្ថកិច្ច ដោយសារមានចំណេះដឹង និងតួនាទីទៅលើសិស្សរបស់គាត់។<br><br>របៀបនៃការគ្រប់គ្រងថ្នាក់រៀន គឺតាមរបៀបបូរាណ ដោយផ្តោតលើច្បាប់ និងលទ្ធផលរំពឹងទុក។ | គ្រូបង្រៀនឯកទេស គឺជាអ្នកដែលមានចំណេះដឹងទាំងអស់ និងមានបទពិសោធន៍ក្នុងថ្នាក់រៀន។<br><br>ភារកិច្ចចាំបាច់របស់គាត់គឺ ជាអ្នកនាំផ្លូវ និងណែនាំសិស្សតាមរយៈ ដំណើរការរៀន។<br><br>សិស្សត្រូវបានមើលឃើញថាជាអ្នកទទួលចំណេះដឹង និងព័ត៌មាន | គ្រូបង្រៀនតាមគម្រូខ្លួន គឺជាអ្នកនាំសិស្សតាមរយៈឧទាហរណ៍ ការធ្វើបង្ហាញដល់សិស្សអំពីរបៀបរកព័ត៌មាន និងយល់ដឹងពីព័ត៌មាន<br><br>នៅក្នុងការបង្រៀនតាមគម្រូរបស់ខ្លួន សិស្សរៀនតាមរយៈការសង្កេត និងធ្វើតាមលំនាំបង្រៀនរបស់គ្រូ។ |

(ខ) វិធីសាស្ត្រស្រាវជ្រាវ "inquiry-based learning"៖ វិធីសាស្ត្រនេះគឺផ្តោតលើការស្រាវជ្រាវរបស់សិស្ស និងការអនុវត្តផ្ទាល់ "hand-on learning"។ កិច្ចការសំខាន់របស់គ្រូបង្រៀនគឺ ជាអ្នកសម្របសម្រួល ជួយណែនាំ និងជួយសិស្សក្នុងដំណើរការសិក្សា។ វិធីសាស្ត្របង្រៀនផ្អែកលើការស្រាវជ្រាវ "inquiry-based learning" គឺស្ថិតនៅក្នុង**<u>គោលវិធីសិស្សមជ្ឈមណ្ឌល</u>** ដែលសិស្សជាអ្នកដើរតួរសកម្មក្នុងការចូលរួម ក្នុងដំណើរការសិក្សាដោយខ្លួនឯង។

| **អ្នកសម្របសម្រួល**<br><br>Facilitator | **តាមគម្រូខ្លួនបុគ្គល/**<br><br>Personal model | **អ្នកប្រគល់ភារកិច្ច**<br><br>Delegator |
|---|---|---|
| គ្រូបង្រៀនអ្នកសម្របសម្រួល ផ្តោតលើទំនាក់ទំនងរវាងសិស្ស និងគ្រូបង្រៀន។ | គ្រូបង្រៀនតាមគម្រូខ្លួនបុគ្គល/ គឺជាអ្នកនាំសិស្សតាមរយៈឧទាហរណ៍ ការធ្វើបង្ហាញដល់សិស្សអំពីរបៀបរកព័ត៌មាន | គ្រូបង្រៀនដើរតួជាធនធាន "resource" សម្រាប់សិស្ស ឆ្លើយសំណួរទៅសិស្ស និងពិនិត្យដំណើរការទៅតាមតម្រូវការរបស់ |

| | | |
|---|---|---|
| ការបង្រៀនមានការបើកទូលាយក្នុងការធ្វើសកម្មភាពក្នុងថ្នាក់ និងក្រៅថ្នាក់ ដោយមិនមានការផ្តោតខ្លាំង ទៅលើវិធីបង្រៀនដោយនិយាយប្រាប់ "direct instruction" តែគ្រូបង្រៀន និងសិស្សត្រូវធ្វើការងារជាមួយគ្នា ក្នុងដំណើរការរៀន និងបង្រៀន។<br><br>សិស្សរៀនដោយមិនមានការនាំផ្លូវខ្លាំងក្លាពីគ្រូបង្រៀនទេ ដោយបង្កឱកាសឱ្យសិស្សមានឯករាជ្យភាព ដើម្បីអនុវត្តសកម្មភាព និងធ្វើបេកគំហើញ។ | និងយល់ដឹងពីព័ត៌មាន<br><br>នៅក្នុងគម្រូបង្រៀននេះ សិស្សរៀនតាមរយៈការសង្កេត និងធ្វើតាមលំនាំបង្រៀនរបស់គ្រូ។ | សិស្ស។<br><br>គ្រូបង្រៀនដើរតួជាមនុស្សអកម្ម ក្នុងការសិក្សារបស់សិស្ស តែសិស្សជាអ្នកសកម្ម និងជាអ្នកចូលរួមក្នុងសកម្មភាពសិក្សារបស់គេដោយខ្លួនគេ។<br><br>គោលដៅសំខាន់របស់វិធីសាស្ត្រអ្នកប្រគល់ភារកិច្ច គឺបង្កើតឱ្យមានស្វ័យភាព ឬសិស្សមានម្ចាស់ការក្នុងការសិក្សា |

(គ) ការរៀនតាមបែបសហការណ៍ "cooperative learning"៖ វិធីសាស្ត្រសាស្ត្របង្រៀននេះគឺផ្អែកលើវិធីគ្រប់គ្រងថ្នាក់រៀន និងការបង្រៀន ដោយផ្តោតលើធ្វើការងារក្រុម និងភាពស៊ីជម្រៅនៃការសិក្សា គឺផ្សារភ្ជាប់នឹងជីវភាពរស់នៅ។ វិធីសាស្ត្រនេះជម្រុញដល់សិស្ស ឱ្យមានការរីកចំរើនផ្នែកសង្គម និងខ្លឹមសារមេរៀន រួមជាមួយនឹងល្បិចបង្រៀន មានដូចជា គិត ដៃគូរ ចែករំលែក "Think-Pair-Share"។ វិធីសាស្ត្របង្រៀនតាមបែបសហការណ៍ "cooperative learning" គឺស្ថិតក្នុង**<u>គោលវិធីសិស្សមជ្ឈមណ្ឌល</u>** ដោយសារការរៀន ផ្តោតឱ្យសិស្សមានការទទួលខុសត្រូវ ក្នុងការសិក្សា និងការអភិវឌ្ឍ។ វិធីសាស្ត្រនេះគឺមានជំនឿថាសិស្ស រៀនបានប្រសើរ ពេលណាធ្វើការជាមួយដៃគូ/ក្រុម និងរៀនពីដៃគូ/ក្រុម។

| **អ្នកសម្របសម្រួល**<br><br>Facilitator | **អ្នកប្រគលភារកិច្ច**<br><br>Delegator |
|---|---|
| គ្រូបង្រៀនអ្នកសម្របសម្រួល ផ្តោតលើទំនាក់ទំនងរវាងសិស្ស និងគ្រូបង្រៀន។<br><br>ការបង្រៀនមានការបើកទូលាយក្នុងការធ្វើសកម្មភាពក្នុងថ្នាក់ និងក្រៅថ្នាក់ ដោយមិនមានការផ្តោតខ្លាំង ទៅលើវិធី បង្រៀនដោយនិយាយប្រាប់ "direct instruction" តែគ្រូបង្រៀន និងសិស្សត្រូវធ្វើការងារជាមួយគ្នា ក្នុងដំណើរការរៀន និងបង្រៀន។<br><br>សិស្សរៀនដោយមិនមានការនាំផ្លូវ ខ្លាំងក្លាពីគ្រូបង្រៀនទេ ដោយបង្កឱកាសឱ្យសិស្សមានឯករាជ្យភាព ដើម្បីអនុវត្តសកម្មភាព និងធ្វើបេកគំហើញ។ | គ្រូបង្រៀនដើរតួជាធនធាន "resource" សម្រាប់សិស្ស ឆ្លើយសំណួរទៅសិស្ស និងពិនិត្យដំណើរការ ទៅតាមតម្រូវការរបស់សិស្ស។<br><br>គ្រូបង្រៀនដើរតួជាមនុស្សអកម្ម ក្នុងការសិក្សារបស់សិស្ស តែសិស្សជាអ្នកសកម្ម និងជាអ្នកចូលរួមក្នុងសកម្មភាពសិក្សារបស់គេដោយខ្លួនគេ។<br><br>គោលដៅសំខាន់របស់វិធីសាស្ត្រអ្នកប្រគល់ភារកិច្ច គឺបង្កើតឱ្យមានស្វ័យភាព ឬសិស្សមានម្ចាស់ការក្នុងការសិក្សា |

## គ. ឯកសារជំនួយសម្រាប់គ្រូបង្រៀន

ក្នុងការសរសេរសកម្មភាពលម្អិតទៅតាមបំណិនអំណានពាក់ព័ន្ធជាមូលដ្ឋានក្នុងការសរសេរគម្រោងលំនាំបង្រៀនមេរៀនមួយ និងកិច្ចតែងការបង្រៀន ដោយមានបង្ហាញការសរសេរសកម្មភាពលម្អិតទៅតាមបំណិនអំណានពាក់ព័ន្ធតាមដំណាក់កាលមួយៗ។

## ឃ. ឯកសារជំនួយសម្រាប់គ្រូបង្រៀន

ក្នុងការសរសេរគម្រោងលំនាំបង្រៀនមួយមេរៀនមានច្រើនម៉ោងសិក្សាដោយមានបង្ហាញតាមដំណាក់កាលមួយៗ ដោយមានគម្រោងលំនាំបង្រៀនមេរៀនមួយជាឧទាហរណ៍។

## ង. ឯកសារជំនួយសម្រាប់គ្រូបង្រៀន

ក្នុងការសរសេរកិច្ចតែងការបង្រៀនទៅតាមគម្រោងលំនាំបង្រៀនមេរៀនមួយដោយមានបង្ហាញឧទាហរណ៍កិច្ចតែងការបង្រៀនសរុបចំនួន ៤៧ ស្របទៅតាមកម្រិត ឬដំណាក់កាលទាំង៩នៃសៀវភៅស្តង់ដាអំណានថ្នាក់ទី១